**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
សំណុំរឿង រដ្ឋប្បវេណី
លេខ:២២៣
ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០០២
**<u>សាលដីកា</u>**
លេខ:០៣
ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០០៤

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**

បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី១២ ខែមករា ឆ្នាំ២០០៤ ដោយមានសមាសភាពដូចតទៅ:

១-ឯកឧត្តម ............ ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ
២-លោក ................ ជាចៅក្រម
៣-លោក ............. ជាចៅក្រម
៤-លោក ............ ជាចៅក្រមរបាយការណ៍
៥-លោក ................. ជាចៅក្រម
៦-លោក ................. ជាចៅក្រម
៧-លោក ................. ជាចៅក្រម
៨-លោក ................ ជាចៅក្រម
៩-លោក .................. ជាចៅក្រម

**<u>ក្រឡាបញ្ជី</u>**

-កញ្ញា ..................

**<u>តំណាងមហាអយ្យការ</u>**

-លោក ................. ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះលើបណ្តឹងសាទុក្ខលើកទី២ពីសាលដីការដ្ឋប្បវេណីលេខ៩០(គ)ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០១ នៃសំណុំរឿងរដ្ឋប្បវេណីលេខ៣៦ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍រវាង

ដើមចោទឈ្មោះអគស(ម្ចាស់បណ្តឹងសាទុក្ខ)ភេទប្រុស អាយុ៣២ឆ្នាំ ជាតិខ្មែរ មុខរបរយោធា ទីលំនៅសព្វថ្ងៃភូមិចំពុះក្អែក ឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្តាល ។ ឪពុកឈ្មោះអ៊ុច សំផន(ស) ម្តាយឈ្មោះអ៊ុង យ៉ន(ស) ប្រពន្ធឈ្មោះជឈឡមានកូន០២នាក់ ។

មានមេធាវី លោក ............ ។

ចុងចម្លើយឈ្មោះជឈឡ(ចុងបណ្តឹងសាទុក្ខ) ភេទស្រី អាយុ៣២ ជាតិខ្មែរមុខរបរលក់ផ្លែឈើ ទីលំនៅសព្វថ្ងៃភូមិចំពុះក្អែក ឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្តាល។ឪពុកឈ្មោះឡេងប៊ុនហ៊ាង (ស) ម្តាយឈ្មោះជា សែ (រ) ប្តីឈ្មោះអគសមានកូន០២នាក់ ។

មានមេធាវីលោក...............។

**កម្មវត្ថុបណ្ដឹង:ប្ដឹងលែងលះប្រពន្ធ**

បានឃើញបណ្ដឹងសាទុក្ខលើកទី២លខ៨០៨ ចុះថ្ងៃទី២៦ ខែវិច្ឆិកាឆ្នាំ២០០១ របស់ឈ្មោះអគស ប្ដឹងមិនសុខចិត្ត និងសាលដីការដ្ឋប្បវេណីលេខ៩០(គ)ចុះថ្ងៃទី២០ខែវិច្ឆិកា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ត្រង់ ណុចនៃសេចក្ដីសម្រេចទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ២២៣ ចុះថ្ងៃទី២២ខែកក្កដាឆ្នាំ២០០២ របស់តុលាការកំពូល។

តាមពាក្យបណ្ដឹងចុះថ្ងៃទី០៤-០៨-១៩៩៨ របស់លោកអគសប្ដឹងលែងលះប្រពន្ធឈ្មោះដឈឡ ដោយហេតុថា ប្រពន្ធខ្លួនជេរប្រមាថម៉ាក់ងាយ និងដកហូតម៉ូតូពីខ្លួន ខ្លួនអស់មនោសញ្ចេតនាក្នុងការរួមរស់ជាមួយគ្នាទៀតហើយ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ៦៤(ក) ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់តុលាការខេត្ត ខេត្តកណ្ដាល ដែលបានសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងចុះថ្ងៃទី០៤-០៨-១៩៩៨ របស់ដើមចោទ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-បង្គាប់ឱ្យឈ្មោះអគសនិងនាងដឈឡដាច់សមគ្គសង្វាសពីគ្នា ចាប់តាំងពីថ្ងៃនេះតទៅ តាមបញ្ញត្តិមាត្រា៣៩ ចំណុច២នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ។

៣-បង្គាប់ឱ្យឈ្មោះដឈឡស្ថិតនៅក្នុងភាពម៉េម៉ាយចំនួន៣០០ថ្ងៃ គិតចាប់ពីថ្ងៃនេះតទៅ តាមបញ្ញត្តិមាត្រា៣៩ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ។

៤-កូនពីរនាក់ ទីមួយឈ្មោះអសរភេទស្រី កើតឆ្នាំ១៩៩០ កូនទី២ឈ្មោះអចថ ភេទប្រុស កើតឆ្នាំ១៩៩៣ ត្រូវប្រគល់ឱ្យនាងដឈឡ(ចុងចម្លើយ) គ្រប់គ្រងថែរក្សា តែឱ្យឈ្មោះអគសចេញអាហារកិច្ចចិញ្ចឹមកូនទាំង០២នាក់នេះ តាមរបបរដ្ឋកំណត់ជារៀងរាល់ខែចាប់តាំងពីខែវិច្ឆិកា ឆ្នាំ១៩៩៨ និងឧបត្ថម្ភបន្ថែមទៀត តាមលទ្ធភាព និងតាមការព្រមព្រៀងរបស់ដើមចោទ ។ មាតាបិតាត្រូវមានសិទ្ធិ និងករណីយកិច្ចអប់រំ ថែរក្សាចិញ្ចឹមកូន តាមបញ្ញត្តិមាត្រា៧២,៧៣ និង៧៤ នៃច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារ ។

៥-ទ្រព្យសម្បត្តិរួមដែលមានម៉ូតូសេ១០០មួយគ្រឿងតម្លៃ១.០០០ដុល្លាអាមេរិក ទូរទស្សន៍ពណ៌មួយគ្រឿងតម្លៃ២២០ដុល្លាអាមេរិក មាសប្រាក់នៅនឹងខ្លួនចុងចម្លើយ ចំណែកផ្ទះដែលយកទៅធ្វើរោងបាយជាមួយផ្ទះម្ដាយ ត្រូវប្រគល់ឱ្យទៅនាងដឈឡទុកសំរាប់ចិញ្ចឹមកូនតទៅតាមការព្រមព្រៀងរបស់ដើមចោទតាមបញ្ញត្តិមាត្រា៧០នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ។

៦-ទ្រព្យសម្បត្តិដោយឡែករបស់ដើមចោទ ដីលំនៅដ្ឋានមួយកន្លែងមានទំហំ១៩៥៩ ម៉ែត្រការេ ដែលមានព្រំប្រទល់ខាងកើតទល់នឹងដីអៀង មិញ ខាងលិចទល់ផ្លូវ ខាងជើងទល់ដីឈួ គួយ និងខាងត្បូងទល់ដីស៊ីន អៀវ ស្ថិតនៅក្នុងភូមិចំពុះក្អែក ឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្ដាល ត្រូវប្រគល់ឱ្យទៅឈ្មោះអគស(ដើមចោទ) គ្រប់គ្រងប្រើប្រាស់ជាកម្មសិទ្ធិផ្ទាល់ ចាប់តាំងពីថ្ងៃនេះតទៅ តាមបញ្ញត្តិមាត្រា ៧០ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ។

៧-ទុកសិទ្ធិឱ្យដើមចោទទៅសួរសុខទុក្ខកូនបានតាមបញ្ញត្តិមាត្រា៧៥ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ។

៨-សម្រេចទទួលស្គាល់តាមផ្លូវច្បាប់ ការសុំបដិសេធ ប័ណ្ណសំគាល់សិទ្ធិប្រើប្រាស់ដីធ្លីលេខG ១២០៧៥១ ចុះថ្ងៃទី២៧-០២-៩២ ដែលដាក់ជាកម្មសិទ្ធិរួមប្ដីប្រពន្ធចោលជាអាសាបង់ តាមសំណូមពរដើមចោទ ចាប់តាំងពីថ្ងៃនេះតទៅ ។

៩-បង្គាប់ឱ្យឈ្មោះអគសទៅចុះបញ្ជីសំគាល់អចលនទ្រព្យដីលំនៅដ្ឋានទំហំ១៥៥៩ ម៉ែត្រការេ ថាជាទ្រព្យសម្បត្តិដោយឡែករបស់ដើមចោទ នៅនាយកដ្ឋានសុរិយោដី ។

១០-បង្គាប់ឈ្មោះអគសបងប្រាក់ប្រដាប់ក្ដីសរុប៧.០០០៛ ក្នុងនោះពន្ធហ្នឹង និងពន្ធ ចុះបញ្ជីក្ដី ១៨០០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់២០០៛ និងពន្ធលើការស៊ើបអង្កេត៥.០០០៛ ប្រាក់នេះដើមចោទបានបង់រួចហើយ ។

១១-សាលក្រមនេះជំនុំជំរះ ជាសាធារណៈ កំបាំងមុខចុងចម្លើយ ចំពោះមុខដើមចោទបើកផ្លូវប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់ ។

បានឃើញបណ្ដឹងឧទ្ធរណ៍ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៩៩ របស់អ្នកស្រីជឈឡប្ដឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ៦៤(ក) ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់តុលាការខេត្តកណ្ដាល ត្រង់ចំណុចនៃសាលក្រមទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៦៧០ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចដូចតទៅ :

១-ទទួលពាក្យបណ្ដឹងឧទ្ធរណ៍ចុះថ្ងៃទី០៦-០១-១៩៩៩ របស់ឈ្មោះជឈឡទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ៦៤(ក) ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់តុលាការ ខេត្តកណ្ដាល ទុកជាបានការដដែល លើកលែងតែចំណុចទី៦ នៃសេចក្ដីសម្រេចដែលត្រូវបដិសេធចោលចំណុច ក្រៅពីនេះទុកជាបានការដដែល ។

៣-សម្រេចប្រគល់ដីលំនៅដ្ឋានស្ថិតនៅភូមិចំពុះក្អែក ឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្ដាល ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លីលេខ៤១២-០៧៥១ ចុះថ្ងៃទី២៧-០២-៩២ ឱ្យទៅចុងចម្លើយឈ្មោះដឈឡកាន់កាប់ជាកម្មសិទ្ធិតទៅ តាមមាត្រា៧០នៃច្បាប់ស្ដីពីអាពាហ៍ពិពាហ៍និងគ្រួសារ ។

៤-កាត់យកប្រាក់ប្រដាប់ក្ដីជាន់សាលាឧទ្ធរណ៍ចំនួន១៣.០០០៛ គឺពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹង ២៥៥០៛ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់៤៥០៛ ចំណាយលើការប្រគល់ដីកាកោះ៥.០០០៛ និងលើអាជ្ញាធរតុលាការ៥០០០៛ សរុប១៣០០០៛ ។

៥-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្ដី បើកផ្លូវប្ដឹងសាទុក្ខតាមកំណត់ច្បាប់ ។

បានឃើញបណ្ដឹងសាទុក្ខលេខ៣៨៤ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ១៩៩៩ របស់ឈ្មោះអគសប្ដឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណី៦៧០ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ចំណុចទី៣ នៃសេចក្ដីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៥៦ ចុះថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០១ របស់តុលាការកំពូលដែលបានសំរេចដូចតទៅ :

១-ទទួលបណ្ដឹងសាទុក្ខលេខ៣៨៤ ចុះថ្ងៃទី១៧-០៩-១៩៩៩ របស់លោកអគសទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ខ្លះ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ៦៧០ ចុះថ្ងៃទី១៣-០៩-១៩៩៩ របស់សាលាឧទ្ធរណ៍ទុកជាបានការ លើកលែងតែចំណុចទី២ ត្រង់ឃ្លាចុងក្រោយដែលថា លើកលែងតែចំណុចទី៦ នៃសេចក្ដីសម្រេច ដែលត្រូវបដិសេធចោល ចំណុចក្រៅពីនេះទុកជាបានការដដែល និងចំណុចទី៣ ដែលត្រូវទុកជាមោឃៈ ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ១២៣ ចុះថ្ងៃទី១៥-០៣-២០០០ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ត្រង់ចំណុចដែលត្រូវទុកជាមោឃៈខាងលើ ។

៤-រឹបអូសប្រាក់ប្រដាប់ក្ដីដែលលោកអគសបានបង់ទុកនៅតុលការកំពូលចំនួន១៩០០០៛ គឺៈ

-ពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹងចំនួន៤.០០០៛ ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០៛ សម្រាប់ជារង្វាន់ក្រឡា បញ្ជីកាន់ហិបប្រាក់.

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០៛ សរុប១៩.០០០៛ ហើយតម្រូវឱ្យអ្នកស្រីដឈឡ សងប្រាក់ចំនួន១៩.០០០៛ នេះទៅដើមចោទវិញ ។

៥-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០០១ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ៩០(គ) ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចដូចតទៅ :

១-ទទួលជំនុំជំរះសំណុំរឿងរដ្ឋប្បវេណីលេខ៣៦ ចុះថ្ងៃទី២១-០៦-២០០១ របស់សាលា ឧទ្ធរណ៍ តាមអំណាចសាលដីការដ្ឋប្បវេណីលេខ៥៦ ចុះថ្ងៃទី១៩-០៤-២០០១ របស់តុលាការកំពូល ។

២-ដីស្ថិតនៅភូមិចំពុះក្អែកឃុំព្រែកថ្មី ស្រុកកៀនស្វាយ ខេត្តកណ្តាលដែលមានប័ណ្ណសំគាល់ សិទ្ធិប្រើប្រាស់ដីធ្លីលេខ ០១២-០៧៥១ ចុះថ្ងៃទី២៧-០២-១៩៩២ បែងចែកជាបីចំណែក គឺ:

- ១/៣ បានទៅឈ្មោះអគសនិង២/៣ បានទៅនាងជឈឡចាប់ពីពេលសាលដីកានេះ ចូលជាស្ថាពរ ។

៣-សាលដីកានេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹងសាទុក្ខលើកទី២លេខ៤០៨ ចុះថ្ងៃទី២៦ ខែវិច្ឆិកាឆ្នាំ២០០១ របស់ឈ្មោះអគសប្តឹងមិនសុខចិត្តនឹងសាលដីការដ្ឋប្បវេណីលេខ៩០(គ) ចុះថ្ងៃទី២០ខែវិច្ឆិកា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ត្រង់ណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការបៀបលេខ១៩៥ ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៣ របស់តុលាការកំពូលដែល មានខ្លឹមសារនៃសេចក្តីសម្រេច ដូចតទៅ :

១-ចាត់របៀបឱ្យចៅក្រមប្រឹក្សាចុះពិនិត្យដល់ទីតាំងដីទំនាស់ និងផ្ទួសប្លង់បង្ហាញទីតាំងឱ្យបានច្បាស់លាស់ ហើយក្នុងករណីចាំបាច់ ត្រូវធ្វើការស៊ើបអង្កេតបន្ថែម ។

២-សាលដីកានេះ ប្រកាសនាសវនាករជាសាធារណៈ នៅថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៣ ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការថា : សាលដីកពលេខ៩០ (គ) ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០១ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះសម្រេចតាមច្បាប់ ។

បានស្តាប់ចម្លើយរបស់ឈ្មោះអគសនៅពេលជំនុំជំរះថា : ក្នុងការលែងលះប្តីប្រពន្ធនេះ ខ្លួនចុះចេញតែខ្លួនដោយប្រគល់ទ្រព្យសម្បត្តិរួមឲ្យទៅប្រពន្ធ និងកូនទាំងអស់ លើកលែងតែដីមួយកន្លែងដែលមានក្បាល១០ម គុណ ១០០ម ដែលខ្លួនសុំយកពាក់កណ្តាល៥ម និង៥មទៀតឲ្យទៅកូន លើកលែងដី១០មត្រង់ កន្លែងផ្លូម្តាយខ្លួន គឺខ្លួនទុកជាទីសក្ការៈបូជា ព្រោះដីនេះជាដីកេរ្តិ៍ម្តាយរបស់ខ្លួន ចែកឲ្យខ្លួន ឯបងស្រីខ្លួនគឺ គាត់ចែកផ្ទះនៅលើដីនេះឲ្យគាត់ ហើយខ្លួន និងប្រពន្ធខ្លួនបានទិញផ្ទះនោះពីបងស្រីខ្លួនយក ហើយផ្ទះនោះបានយកទៅធ្វើផ្ទះបាយនៅខាងផ្ទះម្តាយក្មេកខ្លួនអស់ហើយ ។

បានស្តាប់ចម្លើយរបស់ឈ្មោះជជទទួលសិទ្ធិពីបងស្រីជឈឡនៅពេលជំនុំជំរះថា : ម្តាយខ្លួនជាអ្នកយកលុយមួយតំឡឹងកន្លះមាសនេះទៅទិញដី ពីបងស្រីលោកអគសមិនមែនទិញតែផ្ទះទេ ហើយបើ

គាត់និយាយពីកេរ្តិ៍នោះគឺខុសហើយ រយៈពេលប្រាំមួយប្រាំពីរឆ្នាំនេះលោកអគសបានចុះចេញ ពីផ្ទះដោយមិនបានចិញ្ចឹមកូនមួយរៀលណាទេ ក្នុងនាមគាត់ជាឪពុក មានតែបងស្រីខ្លួនទេ ជាអ្នកចិញ្ចឹមកូនពីរ នាក់នោះ។ ខ្លួនសំណូមពរ សុំឲ្យតុលាការផ្តល់យុត្តិធម៌ដោយប្រគល់ដីនោះឲ្យទៅកូនទាំងអស់ បើប្រពន្ធមិនបានចំនែក ប្តីក៏មិនបានចំនែកដែរ គឺដីនោះត្រូវប្រគល់ឲ្យកូនទាំងអស់ ។

បានស្តាប់ចម្លើយបន្ថែមរបស់លោកអគសនៅពេលជំនុំជំរះថា ប្អូននេះថា ខ្លួនមិនបានចិញ្ចឹមកូនចុះអាហារកិច្ចរាល់ខែ ដែលនាងជឈឡទៅបើកនោះជាអ្វី មិនមែនលុយខ្លួនចិញ្ចឹមកូនទេឬ។ ខ្លួន នៅតែសុំយកដីនោះពាក់កណ្តាល និងពាក់កណ្តាលទៀតខ្លួនប្រគល់ឲ្យកូន ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់លោក........... ជាមេធាវីការពារឱ្យដើមចោទ នៅពេលសវនាការថា :

កម្មវត្ថុបណ្តឹងគឺទាក់ទងទៅនឹងដីកេរ្តិ៍មួយកន្លែង ដែលម្តាយលោកអគសបានចែកឲ្យលោក និងចែកផ្ទះឲ្យបងស្រីលោកអគស។នៅឆ្នាំ១៩៨៩កូនក្តីខ្លួនបានរៀបការជាមួយអ្នកស្រីជឈឡក្រោយមកដោយរស់នៅមិនចុះសំរុងគ្នា ក៏បានលែងលះគ្នា ដោយប្រគល់ទ្រព្យសម្បត្តិរួមទាំងអស់ឲ្យទៅប្រពន្ធ។ ហើយក្នុងការអះអាងថា អ្នកស្រីបានទិញដីនិងផ្ទះនោះ ពុំមានភស្តុតាងណាសម្រាប់យកមកបញ្ជាក់នោះទេ ហើយចំពោះសាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីនោះក៏មានចំណុចខុសឆ្គងដែរ ។ កូនក្តីខ្លួនសុំសំណូមពរគ្រប់គ្រង ដីពាក់កណ្តាល តាមគំនូសប្លង់ចុះអង្កេតរបស់តុលាការ គឺមួយផ្នែកខាងត្បូង និង១ផ្នែកខាងជើងចែកឲ្យកូន ដោយដកទុក១០ម ត្រង់កន្លែងផ្នូរម្តាយទុកជាទីសក្ការះបូជា ។

បានស្តាប់សេចក្តីសន្និដ្ឋានរបស់ឈ្មោះ............. ជាមេធាវីការពារឱ្យចុងចម្លើយនាពេលសវនាការថាៈដីនេះគឺទ្រព្យសម្បត្តិរួមរវាងប្តីប្រពន្ធទាំងពីរនាក់ ដោយផ្អែកលើបង្កាន់ដៃ ។ បើដីនេះពាក់កណ្តាលជាចំណែកឱ្យលោកអគសនិងពាក់កណ្តាលទៀតឲ្យទៅកូន ហើយអ្នកស្រីជឈឡគ្មានចំណែកនោះជា ការអយុត្តិធម៌ណាស់ ក្នុងនាមនាងជាស្ត្រីមេមាយដែលខ្លួនរកស៊ីចិញ្ចឹមកូន នាងមានទុក្ខសោកច្រើនណាស់ សូមតុលាការអនុគ្រោះដល់ស្ត្រីមេមាយផង ហើយមួយវិញទៀតបើថា ដីទំនាស់នោះវាជាចំនែកតិចតួចណាស់ខ្លួនសុំ សំណូមពរ សុំប្រគល់ឲ្យទៅកូនទាំងអស់ទៅ ដើម្បីឲ្យកូនរស់នៅ ហើយគោរពបូជាផ្នូលោកយាយទៅ ចៅក៏អាចគោរពបូជាបានដែរ ។ សំណូមពរចុងក្រោយសូមតម្កល់សាលដីកាលេខ៦៧០ របស់សាលាឧទ្ធរណ៍ ទុកជាបានការពេញទាំងមូល ។

បានស្តាប់សេចក្តីសន្និដ្ឋានបន្ថែមរបស់លោកទឡនៅពេលជំនុំជំរះថា : ខ្លួនគ្រាន់តែសុំលើក ឡើងបីចំណុចតបទៅ និងលោកមេធាវិញថា :

ទី១ សូមពិនិត្យពីស្ថានភាពអ្នកក្រ និងស្ថានភាពអ្នកមានលោកអគសគាត់ទីទាល់ក្រ ជួលផ្ទះគេនៅទេសព្វថ្ងៃនេះ ។

ទី២ លោកថាប្រគល់ឲ្យទៅកូនក៏អាចគោរពបូជាបាន ចុះក្នុងនាមគាត់ជាឪពុកនោះ តើ គិតយ៉ាងណា គាត់មិនរិតតែត្រូវគោរពបូជាជាងចៅទៅទៀត។

ទី៣ លោកថាអ្នកស្រីជាស្ត្រីមេមាយ តើសព្វថ្ងៃនេះគាត់មេមាយ រឺ ក៏មានប្តីហើយ ?។

-ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ចម្លើយរបស់គូភាគី និងសេចក្តីសន្និដ្ឋានរបស់មេធាវីគូភាគី

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

- យល់ឃើញថា បណ្តឹងសាទុក្ខលើកទី២លខ៤០៨ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០១ របស់លោកអគសធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះ មកជំនុំជំរះដល់អង្គសេចក្តីបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា២២៦ នៃច្បាប់ស្តីពីនីតិវិធី ព្រហ្មទណ្ឌដែលមានអានុភាពផងដែរ ក្នុងរឿងរដ្ឋប្បវេណី ។

-យល់ឃើញថា ការលើកឡើងរបស់លោកអគសក្នុងសារណាចុះថ្ងៃទី១៦ ខែសីហាឆ្នាំ២០០២ ថាដីសង់លំនៅដ្ឋាន ដែលមានប័ណ្ណសំគាល់សិទ្ធិកាន់កាប់លេខG-12075 ចុះថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ១៩៩២ ជាទ្រព្យដោយឡែក នោះគឺជាការពុំត្រឹមត្រូវឡើយ ពីព្រោះថានៅលើប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ខាងលើនេះមានបញ្ជាក់ថា ជាទ្រព្យសម្បត្តិរួមប្តី-ប្រពន្ធ ដែលគប្បីបែងចែកតាមមាត្រា៧០ នៃច្បាប់ស្តីពីអាពាហ៍ ពិពាហ៍ និងគ្រួសារ ។

- យល់ឃើញថា ការដែលសាលាឧទ្ធរណ៍សម្រេចប្រគល់ដីទំនាស់ទំហំ $\frac{1}{2}$ ឱ្យដើមចោទ និងប្រគល់ដីឱ្យចុងចម្លើយ ដោយអាងហេតុថា អ្នកស្រីជឈឡទទួលបន្ទុកចិញ្ចឹមកូន ហើយអាហារកិច្ចតាមរបបរដ្ឋកំណត់ពុំគ្រប់គ្រាន់នោះ គឺជាការពុំត្រឹមត្រូវទេ ពីព្រោះថា ទ្រព្យសម្បត្តិរួមទាំងអស់ក្រៅពីដីនេះ តុលាការបាន ប្រគល់ឱ្យចុងចម្លើយអស់ហើយ ដោយមានទាំងអាហារកិច្ចផង ។ ម្យ៉ាងទៀតទំហំដី $\frac{1}{2}$ នេះ ពុំអាចឱ្យដើមចោទ សង់លំនៅដ្ឋានបានសមរម្យទេ ហើយការបែងចែកនេះ អាចមានការប៉ះពាល់ទៅដល់ទីតាំងផ្លូសពម្តាយរបស់ ដើមចោទផងដែរ ។

- យល់ឃើញថា ដើម្បីឱ្យងាយស្រួលក្នុងការអនុវត្តសាលដីកាស្ថាពរ និងធានាផលប្រយោជន៍គូភាគីតុលាការកំពូលគប្បីធ្វើការបែងចែកដីទំនាស់តាមចំណុចគោលABCDEFGHIJKLMN ក្នុប្លង់ទីតាំងដីទំនាស់ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់ចៅក្រមតុលាការកំពូល ដោយបន្ទាត់ត្រង់IJKLស្របជាមួយបន្ទាត់AHGF និងBCDE ហើយAI=IB=FL=LE=500 ម៉ែត្របន្ទាត់ MC-ND=2.00 ម៉ែត្រ និង CD=HG=1000 ម៉ែត្រ ។

- យល់ឃើញថា នៅលើដីទំនាស់មានផ្នូម្ដាយរបស់ដើមចោទ ដែលបរិវេណនេះគ្មានជនណាអាចបំពារបំពានបានទេ គប្បីប្រគល់ទីតាំងដីផ្នូរអេរ HJMNK GH ឱ្យទៅដើមចោទកាន់កាប់គ្រប់គ្រង ហើយដីក្រៅ ពីទីតាំងនេះត្រូវបែងចែកជាពីរចំណែកស្មើគ្នា តាមមាត្រា៧០នៃច្បាប់ស្ដីពីអាពាហ៍ពិពាំ និងគ្រួសារ ។

- យល់ឃើញថា សាលដីការដ្ឋប្បវេណីលេខ៩០(គ) ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០១ របស់សាលា ឧទ្ធរណ៍ ដែលបានសម្រេចសេចក្ដីមកនេះ មានលក្ខណៈខុសឆ្គងទាំងទម្រង់ ទាំងគតិច្បាប់ ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្ដីចំពោះមុខគូក្ដី**

១- ទទួលបណ្ដឹងសាទុក្ខលើកទី២លខ៤០៨ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០១ របស់លោកអគសទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២- ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ៩០(គ) ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០០១ របស់សាលាឧទ្ធរណទាំងមូល ។

៣- សម្រេចបែងចែកដីទំនាស់ជាពីរចំណែកតាមគំនូសប្លង់ ចុះថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ២០០៣ របស់ ចៅក្រមតុលាការកំពូល គឺ:

ក-/ផ្នែកខាងត្បូងទំហំAIJMNKLFGHA ត្រូវប្រគល់ឲ្យលោកអគស។

ខ-/ ផ្នែកខាងជើងទំហំBCDEDELKNMJB ត្រូវប្រគល់ឱ្យអ្នកស្រីជឈឡ។

៤- រឹបអូសប្រាក់ប្រដាប់ក្ដី ចំនួន១៩.០០០រៀល ដែលលោកអគសបានបង់រួចហើយ គឺ :

- ពន្ធចុះបញ្ជីក្ដី និងពន្ធហ្នឹងចំនួន៤០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន៨០០រៀល សម្រាប់ជា រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ។

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន១៥.០០០រៀល សរុប១៩.០០០រៀល ហើយតម្រូវឱ្យអ្នកស្រីជឈឡសងប្រាក់១៩.០០០រៀលនេះ ទៅដើមចោទវិញ ។

៥-សាលដីកានេះ ជំនុំជំរះនៅថ្ងៃទី១២ ខែមករា ឆ្នាំ២០០៤ និងប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី១៩ ខែមករា ឆ្នាំ២០០៤ ។